ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ០៧៥ សណ.១៧/អអក

ភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧

# សេចក្ដីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្ដីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អេស.ខេ.ភី. អិន.ខេ អ៊ិនវេសមិុន សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកសំពៅលូន ស្រុកភ្នំព្រឹក ស្រុកកំរៀង ស្រុកបវេល ខេត្តបាត់ដំបង ស្រុកម៉ាឡៃ និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកបវេល ខេត្តបាត់ដំបង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អេស.ខេ.ភី.អិន.ខេ អ៊ិនវេសមិុន ដើម្បីអនុញ្ញាតឲ្យពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយដែលមានស្រាប់តាមខ្លឹមសារសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្ដល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងផ្ដល់ជូនក្រុមហ៊ុន អេស.ខេ.ភី.អិន.ខេ អ៊ិនវេសមិុន ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ.............................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុកបវេល ខេត្តបាត់ដំបង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្ដល់យោបល់លើខ្លឹមសារនៃការចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យក្រុមហ៊ុន អេស.ខេ.ភី.អិន.ខេ អ៊ិនវេសមិុន អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្ដល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា "**អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ**" ។៚

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្ដាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៥

**លើឯកសារអាជ្ញាបណ្ណលេខ ៤០៣ ឯអ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ សម្រាប់ក្រុមហ៊ុន អេស.ខេ.ភី.អិន.ខេ អ៊ិនវេសមិន ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកសំពៅលូន ស្រុកភ្នំព្រឹក ស្រុកកំរៀង ស្រុកបវេល ខេត្តបាត់ដំបង ស្រុកម៉ាឡៃ និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ**

## សម្រាប់ការពង្រីកតំបន់ចែកចាយ

## DECISION ON THE FIFTH REVISION

OF THE LICENSE DOCUMENT No.403 LD DATED FEBRUARY 25, 2015 OF S.K.P.N.K. INVESTMENT CO., LTD FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF SAMPOV LOUN, PHNOM PREK, KAMREANG, BAVEL DISTRICTS, BATTAMBANG PROVINCE, MALAY DISTRICT AND KRONG POIPET, BANTEAY MEANCHEY PROVINCE

## FOR EXTENDING DISTRIBUTION AREA

**ថ្ងៃទី ...ខែ...... ឆ្នាំ២០១៧**

... ... ..., 2017